# ប្រាសាទព្រះបាលីល័យ

ព្រះបាលីល័យស្ថិតនៅក្នុងបរិវេណអង្គរធំ ផ្លូវទៅទ្វារដីឆ្នាំង នៅពីក្រោយវត្តទេពប្រណម (រូបលេខ១)។ ប្រាសាទនេះមានតួប៉មតែមួយធ្វើអំពីថ្មភក់សាងនៅលើខឿនខ្ពស់ (រូបលេខ២) ព័ទ្ធជុំវិញដោយកំពែងមួយជាន់ធ្វើអំពីថ្មបាយក្រៀម និងមានខ្លោងទ្វារចូលពីខាងកើតធ្វើអំពីថ្មភក់និងថ្មបាយក្រៀម។ លក្ខណៈសំណង់នៃប្រាសាទនេះហាក់ខុសប្លែកពីប្រាសាទខ្មែរដទៃទៀត។ សូមបញ្ជាក់ថា បើយោងតាមសិលាចារឹកមួយនៅក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ ដែលគ្រងរាជ្យនៅចុងស.វទី៩ ដល់ដើមស.វទី១០ បាននិយាយថាមានអាស្រមពុទ្ធសាសនាឈ្មោះ "**សៅគតាស្រម**" (Saugatāśrama) ដែលមានទីតាំងនៅប្រាសាទព្រះបាលីល័យ និងទេពប្រណម[១]។

ដោយសារប្រាសាទនេះគ្មានសិលាចារឹក ដូច្នេះពិបាកនឹងកំណត់កាលបរិច្ឆេទពិតប្រាកដនៃឆ្នាំដែលសាងប្រាសាទនេះ។ យោងតាមលោក ហង់រី ម៉ាសាល់ (Henri Marchal) ដែលសិក្សាអំពីការវិវត្តន៍នៃស្ថាបត្យកម្ម និងសិល្បៈ លោកសន្និដ្ឋានថាតួប៉មនិងខឿនបានសាងនៅស.វទី១២ ហើយខ្លោងទ្វារចូល និងចម្លាក់ទាក់ទងនឹងពុទ្ធសាសនាថេរវាទ គឺសាងនៅស.វទី១៣[២]។ បើទោះបីមានសេចក្តីសន្និដ្ឋាន ខ្លះថាប្រាសាទ នេះអាចសាងនៅក្នុងរាជ្យរបស់ព្រះបាទ **ធរនិន្ទ្រវរ្ម័ន** (ស.វទី១២) ដែលជាព្រះបិតារបស់ ព្រះបាទជ័យវរ្ម័នទី៧ក្តី ប៉ុន្តែអ្នកស្រាវជ្រាវភាគច្រើនបានកំណត់ថាប្រាសាទនេះសាងនៅ ស.វទី១៣ ឧទ្ទិសដល់ព្រះពុទ្ធសាសនា[៣]។

ចម្លាក់នៅលើហោជាង និងផ្តែនៃខ្លោងទ្វារចូល (ខ្លះនិយមហៅ "គោបុរៈ Gopura"?) បង្ហាញអំពីដំណើររឿងរបស់ព្រះពុទ្ធ ដូចជាចម្លាក់នៅលើផ្តែបង្ហាញអំពីព្រះពុទ្ធចូលនិព្វានស្រាប់(រូបលេខ៣)។ យើងពុំដឹងឈ្មោះដើមរបស់ប្រាសាទនេះទេ ប៉ុន្តែឈ្មោះ

---

[១] Cœdès 1932: 84-85

[២] Marchal 1922: 101-134

[៣] Groslier 1973, Thompson 1999

អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ

“**បាលីល័យ**” ដែលគេហៅសព្វថ្ងៃនេះ ប្រហែលក្លាយមកពីឈ្មោះនៃព្រៃមួយដែលព្រះពុទ្ធអង្គ លោកគង់បន្ទាប់ពីនិមន្តចេញពីព្រះរាជវាំងកោសម្ពិ ពោលគឺព្រៃ “**បាលិល័យក**” (Palilayaka) ហើយជាទីដែលមានដំរីពីរឈ្មោះ “**បាលិល័យ**” មកបម្រើព្រះអង្គ។ សេចក្តីសន្និដ្ឋាននេះ គឺផ្អែកលើចម្លាក់នៃហោជាងនៃខ្លោងទ្វារ (ផ្នែកខាងជើង) របស់ប្រាសាទនេះផ្ទាល់ បង្ហាញអំពីវគ្គមួយពេលដែលព្រះអង្គគង់នៅក្នុងព្រៃទទួលចង្ហាន់ពីដំរីទាំងពីរនោះ (រូបលេខ២៤)។

ឈ្មោះនៃប្រាសាទនេះ ខ្លះហៅ “ព្រះប៉ាលីល័យ” ដែលប្រហែលជាការបញ្ចេញសំឡេងតាមភាសាថៃ “ប៉ា” ជាងសំឡេង “បា” ប៉ុន្តែបើតាមមាត់ខ្មែរ គឺត្រូវហៅ “ព្រះបាលីល័យ”។

អរិយធម៌ខ្មែរ AMS KHMER CIVILIZATION

## ឯកសារយោង


Cœdès, George.

1932. “A la Recherché du Yaśodharaśrama.” *BEFEO*, Vol. 32, Paris, pp. 84-85.

Groslier, B. Ph.

1973. *Inscriptions du Bayon*. Mémoire Archéologiques, EFEO, Paris.

Marchal, Henri.

1922. “Le temple de Preah Paliya.” *BEFEO*, Vol. 22, Hanoi, pp. 101-134.

Thompson, Ashley.

1999. *Mémoires du Cambodge*. Thèse pour obtenir le grade de Docteur de l’Université de Paris 8.


អត្ថបទដោយ៖ លោក ញឹម សុជារិទ្ធ



រូបលេខ១



រូបលេខ២



រូបលេខ៣



រូបលេខ៤

អត្ថបទដោយ៖ លោក ញឹម សុជារិទ្ធ